**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

លេខ...៧២៦.....សហវ.ប្រក

រាជធានីភ្នំពេញ, ថ្ងៃទី ២៩ ខែកញ្ញា ឆ្នាំ២០១០

# ប្រកាស

# ស្តីពី

# ការបង្កើតក្រុមការងារ
# ជំរុញការប្រមូលចំណូលពី វិស័យប្រៃសណីយ៍ ទូរគមនាគមន៍ លិខិតឆ្លងដែន វិជ្ជាការ និងវិស័យអាកាសចរស៊ីវិល

## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងប្រព្រឹត្តទៅនៃទីស្តីការគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសអោយប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ៨២អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីបទបញ្ជាទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ០៤អនក្រ.បក ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ០៦អនក្រ.បក ចុះថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០០៣ ស្តីពីការបង្កើតនាយកដ្ឋានហិរញ្ញវត្ថុមូលដ្ឋាន នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, khan Daun Penh, Phnom Penh, CAMBODIA.
www.mef.gov.kh
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-...
Phone : 855-23-724 664 Fax : 855-23-427 798
mef_adm@yahoo.com

- បានឃើញអនុក្រឹត្យលេខ ៧៨អនក្រ.បក ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០០៤ ស្តីពីការបំពេញបន្ថែម និងកែសម្រួលនាយកដ្ឋានមួយចំនួន នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៣៤អនក្រ.បក ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតម្លើងទីចាត់ការគយ និងរដ្ឋាករ នាយកដ្ឋានពន្ធដារ និងរតនាគារជាតិ អោយទៅជាអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា អគ្គនាយកដ្ឋានពន្ធដារ និងអគ្គនាយកដ្ឋានរតនាគារជាតិ ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- តាមតម្រូវការចាំបាច់របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## សម្រេច

**ប្រការ១:** ត្រូវបានបង្កើតក្រុមការងារកៀរគរចំណូលពី វិស័យប្រៃសណីយ៍ ទូរគមនាគមន៍លិខិតឆ្លងដែន ទិដ្ឋាការ និងវិស័យអាកាសចរស៊ីវិល ដែលមានសមាសភាព ដូចខាងក្រោម:

| | | |
|---|---|---|
| ១- ឯកឧត្តម **អ៊ុំ ម៉ុនឡុង** | រដ្ឋលេខាធិការ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ប្រធាន |
| ២- ឯកឧត្តម **ខឿ ទិស្សេត** | អគ្គលេខាធិការ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | អនុប្រធាន |
| ៣- ឯកឧត្តម **ញឹម ខេមរា** | អគ្គលេខាធិការរង ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | អនុប្រធានប្រចាំការ |
| ៤- លោក **អ៊ូន ម៉ុនឃាត់** | ប្រធាន នាយកដ្ឋាន ចំណូលមិនមែនសារពើពន្ធ | សមាជិក |
| ៥- លោក **ខឹម រិទ្ធីសែន** | ប្រធាន នាយកដ្ឋានចំណូល-ចំណាយថវិកាជាតិ អគ្គនាយកដ្ឋានរតនាគារជាតិ | សមាជិក |
| ៦- លោក **ចែម ចាសនា** | ប្រធាន នាយកដ្ឋានសេវាអ្នកជាប់ពន្ធ និងបំណុលពន្ធ អគ្គនាយកដ្ឋានពន្ធដារ | សមាជិក |
| ៧- លោក **ម៉ែន ទុត្ថា** | អនុប្រធានទី១ នាយកដ្ឋានចំណូលមិនមែនសារពើពន្ធ | សមាជិក |
| ៨- លោក **គុយ សៀ** | ប្រធានការិយាល័យទី៣ នាយកដ្ឋានចំណូលមិនមែនសារពើពន្ធ | សមាជិក |
| ៩- លោក **រស់ ម៉ារឌី** | ប្រធាន ក្រុមមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុអម ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ | សមាជិក |
| ១០- លោក **ចាន់ ផល** | ប្រធាន ក្រុមមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុអម ក្រសួងមហាផ្ទៃផ្នែកសន្តិសុខសាធារណៈ | សមាជិក |
| ១១- លោកស្រី **សិន ម៉ូលីវណ្ណា** | ប្រធាន ក្រុមមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុអម រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល | សមាជិក |
| ១២- លោក **ស៊ុនលី ធារិទ្ធ** | ជំនួយការ អគ្គលេខាធិការ | សមាជិក |
| ១៣- លោកស្រី **ហ៊ុំ សូរីដា** | អនុប្រធានការិយាល័យទី៣ នាយកដ្ឋានចំណូលមិនមែនសារពើពន្ធ | សមាជិក |
| ១៤- លោក **ពៅ កញ្ញា** | អនុប្រធាន ក្រុមមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុអម ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ | សមាជិក |
| ១៥- លោកស្រី **ឃ្លុក ម៉ុះឡៀម** | អនុប្រធានការិយាល័យទី១ នាយកដ្ឋានចំណូលមិនមែនសារពើពន្ធ | លេខាធិការ |

**ប្រការ២:** ក្រុមការងារនេះមានតួនាទី និងភារកិច្ចដូចតទៅៈ

- ជាសេនាធិការអោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុក្នុងការជំរុញតឹងទារបំណុល និងចំណូលបានមកពី វិស័យ ប្រៃសណីយ៍ ទូរគមនាគមន៍ លិខិតឆ្លងដែន ទិដ្ឋាការ និងវិស័យអាកាសចរស៊ីវិល ។
- ពិនិត្យតាមដាន និងដាក់ចេញវិធានការជាប្រចាំ ដើម្បីជម្រុញតឹងទារបំណុល និងចំណូលបានមកពី វិស័យ ប្រៃសណីយ៍ ទូរគមនាគមន៍ លិខិតឆ្លងដែន ទិដ្ឋាការ និងវិស័យអាកាសចរស៊ីវិល ។
- ពិនិត្យទិដ្ឋភាពផ្លូវច្បាប់ ដើម្បីរកលទ្ធភាពសើរើ ឬលប់កិច្ចសន្យាវិនិយោគ និងកិច្ចសន្យាផ្សេងៗ ដែលមិនបាន អនុវត្តត្រឹមត្រូវតាមលក្ខខណ្ឌកំណត់ ឬធ្វើអោយរដ្ឋខាតបង់ចំណូល ។
- រាយការណ៍អំពីលទ្ធផលការងារដែលសម្រេចបានជូនរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីស្នើសុំសេចក្តីសម្រេច និងការណែនាំបន្ថែម ។

**ប្រការ៣:** អនុប្រធាន សមាជិក ត្រូវចូលរួមប្រជុំ តាមការអញ្ជើញរបស់ប្រធាន ។ ប្រធានអាចផ្ទេរសិទ្ធិជូនអនុប្រធាន ដើម្បីដឹកនាំការងារជំនួស ក្នុងករណីមានធុរៈជាយថាហេតុ ។

**ប្រការ៤:** រាល់លិខិតបទដ្ឋានដែលផ្ទុយពីការប្រកាសនេះ ចាត់ទុកជានិរាករណ៍ ។

**ប្រការ៥:** អគ្គលេខាធិការ ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក នាយកខុទ្ទកាល័យ អគ្គាធិការ គ្រប់នាយកដ្ឋាន និងអង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ព្រមទាំងសមាសភាពដូចមានចែងក្នុងប្រការ ១ ខាងលើត្រូវសហការ និងអនុវត្តការងារអោយមានប្រសិទ្ធភាពតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**គាត ឈន់**

***កន្លែងទទួល:***

- *ទីស្តីការគណៈរដ្ឋមន្ត្រី*
- *ក្រសួង-ស្ថាប័នពាក់ព័ន្ធ*
- *ខុទ្ទកាល័យ សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី*
- *ឯកសារ-កាលប្បវត្តិ*